# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## ស្តីពីនិតិវិធីផ្តល់ប្រាក់ឧបត្ថម្ភក្នុងអន្លង់ពេលព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងនេះធ្វើឡើងរវាង ក្រុមហ៊ុនអៅដរ ហ្គៀ(ខេមបូឌា) ឯ.ក និងប្រតិភូបុគ្គលប្រចាំរោងចក្រ ។

ភាគីក្រុមហ៊ុនហៅថា **ភាគី"ក"** ភាគីប្រតិភូបុគ្គលនិងសហជីពមូលដ្ឋានហៅថា **ភាគី"ខ"**

**ភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការចុះកិច្ចព្រមព្រៀងដែលមានលក្ខខណ្ឌដូចខាងក្រោម:**

**ប្រការ១:** ក្រុមហ៊ុនអៅដរ ហ្គៀ(ខេមបូឌា) ឯ.កនិងអនុវត្តតាមសេចក្តីប្រកាសរបស់ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ០៤៥/២០ ក.ប.ស.ណ.ខ.ល ស្តីពីការព្យួរកិច្ចសន្យាការងារ។

**១. កម្មករនិយោជិតត្រូវទទួលបានប្រាក់ឧបត្ថម្ភពីនិយោជក**

សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ត្រូវផ្តល់ប្រាក់ឧបត្ថម្ភក្នុងអន្លង់ពេលព្យួរកិច្ចសន្យាការងារដូចខាងក្រោម:

- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន១០ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងារមានរយៈពេល៧ថ្ងៃ ដល់១០ថ្ងៃ។
- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន២០ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងារមានរយៈពេល១១ថ្ងៃ ដល់ ២០ថ្ងៃ។
- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន៣០ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងារមានរយៈពេល ២១ថ្ងៃ ដល់១ខែ។

**២. កម្មករនិយោជិតត្រូវទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលដូចខាងក្រោម:**

- ចំនួន១៥ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងារមានរយៈពេល៧ថ្ងៃ ដល់១០ថ្ងៃ។
- ចំនួន៣០ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងារមានរយៈពេល១១ថ្ងៃ ដល់ ២០ថ្ងៃ។
- ចំនួន៤០ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងារមានរយៈពេល ២១ថ្ងៃ ដល់១ខែ។

**ប្រការ២:** ភាគីទាំងពីរបានព្រមព្រៀងគ្នាបើកប្រាក់ឧបត្ថម្ភ ព្យួរកិច្ចសន្យាខាងលើ រៀងរាល់ ថ្ងៃទី១០នៃខែនិមួយៗ។

ប្រការ៣: ការអនុវត្តព្យួរកិច្ចសន្យាការងារលើកទី២ ចំនួន១៧០នាក់ ស្រី ១៥០នាក់ រយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាព និងអនុវត្តចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០នេះតទៅ។

ប្រតិភូបុគ្គល

កែម សុធា　　អិរ គៀក　　បុង ស្រស់

ធន សេរី　　ទឹម ពៅ　　ប៊ិន យុក

អៅដរ, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

**នាយកក្រុមហ៊ុន**

Wu Mei

Scanned with CamScanner